អង្គការទិន្នន័យអំពីការអភិវឌ្ឍ
Open Development Cambodia
www.opendevcam.net
OpenDevCam
@OpenDevCam
(+855) 23 902 196
contact@opendevcam.net

# សិក្ខាសាលាបណ្តុះបណ្តាលស្តីពី មូលដ្ឋានគ្រឹះនៃ QGIS

## ការណែនាំ៖

អង្គការទិន្នន័យអំពីការអភិវឌ្ឍហៅកាត់ថាអូឌីស៊ី គឺជាគេហទំព័របែប "ទិន្នន័យបើកទូលាយ"។ គេហទំព័រប្រភេទនេះ ជាគេហទំព័រដំបូងគេបង្អស់នៅតំបន់អាស៊ី-អាគ្នេយ៍។ ចលនា"ទិន្នន័យបើកទូលាយ" គឺផ្អែកលើការសន្មត់ដ៏សាមញ្ញមួយគឺថា ទិន្នន័យទាំងឡាយណាដែលត្រូវបានប្រមូលផ្តុំសម្រាប់ផលប្រយោជន៍សាធារណៈ គួរតែដាក់ឲ្យប្រើប្រាស់បានជាសាធារណៈ ពោលគឺដោយគ្មានការដាក់ កំហិតឡើយ។ ព័ត៌មាន ឬទិន្នន័យទាក់ទងនឹងវិស័យសាធារណៈគួរផ្តល់ឲ្យដោយ សេរីដល់ គ្រប់ៗគ្នា ដើម្បីប្រើ និងធ្វើការផ្សព្វផ្សាយជាសាធារណៈតាមបំណងប្រាថ្នារបស់គេ។ អូឌីស៊ីមិនធ្វើការលើកស្ទួយឬផ្សព្វផ្សាយទស្សនៈ របៀបវារៈ ឬការលំអៀងណាមួយ ក្រៅពីការផ្តល់ព័ត៌មានជាសត្យានុម័តអំពីប្រទេសកម្ពុជា និងការអភិវឌ្ឍរបស់ប្រទេសនោះឡើយ។

អង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី) មានសេចក្តីសោមនស្សក្នុងការរៀបចំសិក្ខាស្តីពី មូលដ្ឋានគ្រឹះនៃ QGIS ដែលមានរយៈពេល ២ថ្ងៃពេញ នៅថ្ងៃទី០១-០២ ខែសីហា ឆ្នាំ ២០២២ (ចាប់ពីម៉ោង ៨:៣០ព្រឹក ដល់ម៉ោង ៤:៣០នាទីល្ងាច)។ សិក្ខាសាលានេះមានគោលបំណងផ្តល់ជូននូវចំណេះដឹងអំពីប្រព័ន្ធព័ត៌មានភូមិសាស្ត្រ និងការប្រើប្រាស់កម្មវិធី ជីអាយអេសបើកទូលាយ (QGIS) សម្រាប់ការប្រមូលទិន្នន័យ ការគ្រប់គ្រងទិន្នន័យ និងការធ្វើផែនទី។ សិក្ខាសាលានេះនឹងផ្តោតលើប្រធានបទអំពី បរិស្ថាន និងធនធានធម្មជាតិ។

## សិក្ខាសាលា៖

សិក្ខាសាលារយៈពេល ២ថ្ងៃ នេះត្រូវបានរៀបចំឡើងដោយមានមេរៀន សម្រាប់សិក្ខាកាមក្នុងការយល់ដឹងពីគោលការសំខាន់ៗនៃការប្រើប្រាស់ផែនទី និងការអនុវត្តជាក់ស្តែងក្នុងការងារ។ មេរៀនទាំងនោះមានដូចជា៖
ជំពូក១ ៖ ការណែនាំអំពីប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS)
ជំពូក២ ៖ ការចាប់ផ្តើមដំបូងជាមួយកម្មវិធី QGIS
ជំពូក៣៖ ការគ្រប់គ្រងប្រព័ន្ធទិន្នន័យផែនទី
ជំពូក៤៖ ការរចនាទិន្នន័យតាមរយៈការដាក់ពណ៌ និងនិមិត្តសញ្ញា
ជំពូក៥៖ ការរៀបចំ និងបោះពុម្ពផែនទី

## អំពីសិក្ខាសាលា៖

- ទីតាំង៖ **ការិយាល័យអង្គការទិន្នន័យអំពីការអភិវឌ្ឍ ផ្ទះ២៣B ផ្លូវ៦០៦, ភ្នំពេញ**
  តំណភ្ជាប់ផែនទីទីតាំង៖ https://goo.gl/maps/PUb1Sa7hbbdZy6Xv8
- កាលបរិច្ឆេទ៖
  - ថ្ងៃផុតកំណត់ចុះឈ្មោះ៖ ១៨ កក្កដា ២០២២

www.opendevcam.net
OpenDevCam
@OpenDevCam
(+855) 23 902 196
contact@opendevcam.net

  - ថ្ងៃប្រកាសឈ្មោះបេក្ខជន៖ ២៥ កក្កដា ២០២២
  - ថ្ងៃបណ្តុះបណ្តាល៖ ០១-០២ សីហា ២០២២
- អត្ថប្រយោជន៍៖ សិក្សាដោយឥតគិតថ្លៃ វិញ្ញាបនបត្រ អ៊ីនធឺណិត អាហារសម្រន់ និងអាហារថ្ងៃត្រង់
- មេរៀនសិក្សា៖ ភាសាខ្មែរ និងអង់គ្លេស
- តម្រូវការ៖ អ្នកចូលរួមត្រូវមាន កុំព្យូទ័រយួរដៃ ចំណេះដឹងក្នុងការប្រើប្រាស់កុំព្យូទ័រ និងភាសាអង់គ្លេសកម្រិតមូលដ្ឋាន (អាចយល់ពីពាក្យអង់គ្លេសទូទៅបាន)
- សម្រាប់ការចុះឈ្មោះ ៖ https://bit.ly/3Ntt1Rl
- សូមទំនាក់ទំនង៖ លោក ឡុច កល្យាណ, ទូរសព្ទលេខ៖ (៨៥៥)៩៣ ៨៤ ២៩ ១៨
- សារអេឡិចត្រូនិក៖ training@opendevcam.net

**ការសិក្សាដោយឥតគិតថ្លៃ៖**

អូឌីស៊ី នឹងផ្តល់កន្លែងចំនួន ១០ តាមរយៈការចុះឈ្មោះសិក្សារបស់សិក្ខាកាម ដោយមានការជ្រើសរើសចេញពីបញ្ជីចុះឈ្មោះអេឡិចត្រូនិករបស់អង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី)។ បញ្ជាក់៖ ស្ត្រី និងនិស្សិត ដែលធ្វើការពាក់ព័ន្ធទៅនឹងប្រធានបទស្តីអំពីបរិស្ថាន និងធនធានធម្មជាតិ ត្រូវបានលើកទឹកចិត្តក្នុងការចូលរួមសិក្ខាសាលាបណ្តុះបណ្តាលនេះ។